# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: ខ្មែរ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Oct-2014, 14:06
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# បណ្តឹងជំទាស់របស់ នួន ជា សុំដកចៅក្រម ប៉ែន ពេជ្ជសាលី

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

សួន វិសាល

លីវ សុវណ្ណា

Doreen CHEN
Joshua ROSENSWEIG
Xiaoyang NIE
Sophie DAWSON

**ចម្លងជូន:**

**សហមេធាវី ខៀវ សំផន**

គង់ សំអុន

Arthur VERCKEN
Anta GUISSÉ

**សហព្រះរាជអាជ្ញា:**

ជា លាង

Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហមេធាវីការពារក្តីលោក នួន ជា ("មេធាវីការពារក្តី") សូមដាក់បណ្តឹងជំទាស់ដើម្បីដកចៅក្រម ប៉ែន ពេជ្រ សាលីចេញពីសមាសភាពចៅក្រមដែលចាត់តាំងឡើងដោយគណៈកម្មាធិការរដ្ឋបាលតុលាការ ("សមាសភាពចៅក្រមពិសេស")[1] ដើម្បីសម្រេចលើបណ្តឹងជំទាស់របស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និងចៅក្រម យូរ ឧត្តរា ("បណ្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង")[2]។

## II. សារចរ

## ក. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមសំណុំរឿង ០០២/០១[3]។

3. នៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងអំពីបំណងរបស់ខ្លួនអំពីបណ្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង[4]។

4. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៤ សហមេធាវីការពារក្តីរបស់ ខៀវ សំផន បានដាក់សំណើ ("សំណើរបស់ ខៀវ សំផន") សុំឲ្យផ្អាកសំណុំរឿង ០០២/០២ រហូតទាល់តែមានសាលដីកាស្ថាពរលើសំណុំរឿង ០០២/០១ សិន ឬ និយាយម្យ៉ាងទៀតថា សុំប្តឹងជំទាស់ចៅក្រមរបស់អង្គជំនុំ

---

[1] ឯកសារ E314/4 "សេចក្តីសម្រេចរបស់គណៈកម្មាធិការរដ្ឋបាលតុលាការ ទាក់ទងនឹងការចាត់តាំងសមាសភាពចៅក្រមដើម្បីពិនិត្យ និងវិនិច្ឆ័យលើបណ្តឹងជំទាស់ប្រឆាំងនឹងចៅក្រមអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ ទំព័រ ១។

[2] ឯកសារ E314/6 "បណ្តឹងជំទាស់របស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និង ចៅក្រម យូរ ឧត្តរា" ថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ២០១៤។

[3] ឯកសារ E313 "សាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០១៤។

[4] ឯកសារ E314.1 "សេចក្តីជូនដំណឹង និងសំណើទាក់ទងនឹងបណ្តឹងជំទាស់" ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១៤។

ជម្រះទាំងអស់[5]។

5. នៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ គណៈកម្មាធិការរដ្ឋបាលតុលាការបានចាត់តាំងចៅក្រម ធូ មណី (ប្រធាន) ចៅក្រម Judges Rowan Downing ចៅក្រម Chang-ho Chung ចៅក្រម ហួត វុទ្ធី និងចៅក្រម ប៉ែន ពេជ្រសាលី ជាសមាសភាពចៅក្រមដើម្បីសម្រេចលើបណ្តឹងមិនពេញចិត្ត ចៅក្រមអង្គជំនុំជម្រះសាលាដំបូង និងសំណើរបស់ ខៀវ សំផន។

6. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់បណ្តឹងមិនពេញចិត្តចៅក្រមអង្គជំនុំជម្រះសាលាដំបូង។

## ខ. ចៅក្រម ប៉ែន ពេជ្រសាលី

7. ចៅក្រម ប៉ែន ពេជ្រសាលី សព្វថ្ងៃកំពុងបម្រើការជាចៅក្រមបម្រុងនៃអង្គបុរេជំនុំជម្រះ។ ហើយក្នុងពេលជាមួយគ្នាក៏ជាមន្ត្រីបម្រើការពេញម៉ោងនៃក្រសួងយុត្តិធម៌ក្នុងឋានៈជា អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ។[6] មេធាវីការពារក្តីបានយល់ថា ចៅក្រម ប៉ែន ពេជ្រសាលី ត្រូវបានតែងតាំងជាចៅក្រមតាំងពីឆ្នាំ២០០១[7] បើទោះជាគាត់ត្រូវបានតែងតាំងជាចៅក្រមសម្រាប់តែនៅ អ.វ.ត.ក នេះក៏ដោយ។

## III. ច្បាប់ជាធរមាន

### ក. ភាពដាច់ដោយឡែករវាងអង្គការនីតិប្រតិបត្តិ និងតុលាការ

---

[5] ឯកសារ E314/1 "សំណើររបស់លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ" ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៤។

[6] ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៤/១១១៣ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៤ និងសូមមើលគេហទំព័រ អវតក "ចៅក្រម ប៉ែន ពេជ្រសាលី (បម្រុង)" អាចរកបាននៅ http://www.eccc.gov.kh/en/persons/judge-pen-pichsaly-reserve។

[7] គេហទំព័រ អវតក "ចៅក្រម ប៉ែន ពេជ្រសាលី(បម្រុង)" អាចរកបាននៅ http://www.eccc.gov.kh/en/persons/judge-pen-pichsaly-reserve។

8. នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា បានចែងថា អង្គការនីតិប្រតិបត្តិ និងតុលាការត្រូវតែនៅឲ្យដាច់ពីគ្នា[8] និង "គ្មានអង្គការណាមួយអាចទទួលអំណាចតុលាការអ្វីបានឡើយ"[9]។

## ខ. ភាពមិនលម្អៀង និងឯករាជ្យភាពរបស់អង្គចៅក្រម

9. ដូចដែលបានលើកឡើងនៅក្នុងបណ្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងហើយថា សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយតុលាការឯករាជ្យ និងមិនលម្អៀង គឺជាសិទ្ធិមួយដ៏សំខាន់បំផុតរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។[10] សិទ្ធិនេះគឺជា "*សិទ្ធិពេញលេញ*ដែលមិនអាចមានករណីលើកលែងឡើយ"។[11] មានន័យថា សិទ្ធិនេះអនុវត្ត "នៅគ្រប់កាលៈទេសៈទាំងអស់ និងគ្រប់តុលាការទាំងអស់ មិនថាតុលាការធម្មតា ឬតុលាការពិសេសឡើយ"។[12]

10. ចៅក្រម អ.វ.ត.ក ត្រូវតែ "ឯករាជ្យនៅក្នុងការបំពេញការងាររបស់ខ្លួន" ផងដែរ ហើយមិនត្រូវ

---

[8] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រាទី៥១ (៥) "អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ"។

[9] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រាទី ១៣០។

[10] UDHR មាត្រា ១០, ICCPR មាត្រា ១៤(១), ECHR មាត្រា ៦(១), ACHR មាត្រា ៨(១), AfCHPR មាត្រា ៧(១)។ *សូមមើលផងដែរ* រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Furundžija* សាលដីកា សំណុំរឿងលេខ IT-95-17/1-A ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ ("សាលដីការឿងក្តី Furundžija កថាខណ្ឌ ១៧៧។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Nahimana និងអ្នកផ្សេងទៀត "សាលដីកា" សំណុំរឿងលេខ* ICTR-99-52-A ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ("សាលដីការឿងក្តី Nahimana") កថាខណ្ឌ ២៨, ៤៧។

[11] រឿងក្តី *González del Río ទល់នឹង ប្រទេសប៉េរូ* UN HRC, Comm. No. 263/1987, UN Doc. No. CCPR/C/46/D/263/1987 ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩២ កថាខណ្ឌ ៥.២ (សេចក្តីបញ្ជាក់បន្ថែម)។

[12] ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស សហប្រតិបត្តិការជាមួយគណៈមេធាវីអន្តរជាតិ *សិទ្ធិមនុស្សនៅក្នុងរដ្ឋបាលតុលាការ ៖* សៀវភៅណែនាំស្តីអំពីសិទ្ធិមនុស្ស សម្រាប់ចៅក្រម រដ្ឋអាជ្ញា និងមេធាវី ឯកសាររបស់ UN លេខ HR/P/PT/9, ឆ្នាំ ២០០៣ ទំព័រ ១១៨។

"ទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ"។[13] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR បានចាត់ទុកឯករាជ្យភាពរបស់តុលាការជា "លក្ខណៈសម្បត្តិមុខងាររបស់តុលាការ ដែលមានន័យថា ស្ថាប័ន ឬបុគ្គលដែលមានឯករាជ្យភាពមិនស្ថិតនៅក្រោមអំណាចពីខាងក្រៅទេ និងមានសេរីភាពពេញលេញក្នុងការធ្វើសេចក្ដីសម្រេច"។[14] នៅពេលធ្វើការវាយតម្លៃលើឯករាជ្យភាពរបស់តុលាការ ឬសាលាក្ដី តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR) បានពិចារណាយ៉ាងយូរអំពី "លក្ខណៈនៃការតែងតាំងសមាជិករបស់តុលាការ/សាលាក្ដី និងអាណត្តិការងាររបស់សមាជិកទាំងនោះ អត្ថិភាពនៃការការពារប្រឆាំងនឹងសម្ពាធពីខាងក្រៅ និងបញ្ហាថាតើតួអង្គនោះបង្ហាញឱ្យឃើញនូវឯករាជ្យភាពដែរឬទេ"។[15]

## ខ. បណ្ដឹងជំទាស់ចៅក្រម

11. អនុលោមតាមវិធាន ៣៤(២)នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង") លក្ខណៈវិនិច្ឆ័យសម្រាប់សុំជំទាស់ចៅក្រម អ.វ.ត.ក មានដូចខាងក្រោមនេះ ៖

> ភាគីអាចធ្វើបណ្ដឹងជំទាស់ចំពោះសហចៅក្រម ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធ ដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឱ្យមានភាពលម្អៀង។

## គ. បណ្ដឹងជំទាស់លើសមាជិកនៃសមាសភាពចៅក្រម

12. វិធាន ៣៤(៦) ចែងថា:

> ចៅក្រមពេញសិទ្ធិអាចត្រូវជំនួសដោយចៅក្រមបម្រុងនៃអង្គជំនុំជម្រះនោះបាន សម្រាប់តែករណីបណ្ដឹងជំ

---

[13] ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ១០ថ្មី។ *សូមមើល ផងដែរ* លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៤០, លក្ខន្តិកៈតុលាការ STL មាត្រា ៩(១)។

[14] រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Nahimana និងអ្នកផ្សេងទៀត* សាលដីកា សំណុំរឿងលេខ ICTR-99-52-A ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ១៩។

[15] *សូមមើល ឧទាហរណ៍* រឿងក្ដី *Volkov ទល់នឹង ប្រទេសអ៊ុយក្រែន* "សាលក្រម" តុលាការ ECtHR បណ្ដឹងលេខ 21722/11, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ("សាលក្រមរឿងក្ដី Volkov") កថាខណ្ឌ ១០៣, រឿងក្ដី *Findlay ទល់នឹង ចក្រភពអង់គ្លេស* "សាលក្រម" តុលាការ ECtHR បណ្ដឹងលេខ 22107/93 ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ កថាខណ្ឌ ៧៣ (សេចក្ដីបញ្ជាក់បន្ថែម)។

ចិត្តនោះប៉ុណ្ណោះ។ ប្រសិនបើមានពាក្យបណ្ដឹងជំទាស់ច្រើន ដែលមិនអាចរៀបចំអង្គជំនុំជម្រះ ដើម្បីសម្រេចលើពាក្យបណ្ដឹងទាំងនោះបានទេ គណៈកម្មាធិការរដ្ឋបាលតុលាការ ត្រូវជ្រើសរើសចៅក្រមបន្ថែមពីក្នុងចំណោមចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញ។

13. អាស្រ័យហេតុនេះហើយគ្រប់សមាជិកនៃសមាសភាពចៅក្រមត្រូវបានទទួលស្គាល់ថា ជាសមាជិករបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់ដោះស្រាយលើបណ្ដឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ។ វាក៏បង្ហាញឲ្យឃើញថា បណ្ដឹងជំទាស់លើសមាជិកនៃសមាសភាពចៅក្រមត្រូវតែបានដាក់ឡើង ដោយអនុលោមតាមវិធាន ៣៤(៤)(គ) ដែលបានចែងពីតម្រូវការបណ្ដោះអាសន្នសម្រាប់បណ្ដឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង។

## IV. **ឧឡឹករណ៍**

### ក. **បណ្ដឹងនេះបានដាក់ទាន់ពេល ដូច្នេះអាចទទួលយកបាន**

14. មេធាវីការពារក្ដីធ្វើបណ្ដឹងជំទាស់សុំដកចៅក្រម យ៉ែន ពេជ្រសាលី ពីសមាសភាពចៅក្រមគឺមិនមែនគ្រាន់តែដោយសារតួនាទីបច្ចុប្បន្នរបស់គាត់នៅក្នុងអង្គការនីតិប្រតិបត្តិនៅក្នុងរដ្ឋាភិបាល ដែលមេធាវីការពារក្ដីសូមបញ្ជាក់យ៉ាងច្បាស់ទាក់ទងទៅនឹងការគ្រប់គ្រងលើកិច្ចការអយ្យការរបស់គាត់នៅក្នុងស្ថាប័នជាតិនោះទេ តែក៏ដោយសារតែការកាន់តួនាទីបែបនេះ អាចនាំឲ្យគាត់លម្អៀងក្នុងការពិចារណាលើអំណះអំណាងដូចគ្នានៅក្នុងបណ្ដឹងជំទាស់មកលើចៅក្រមអង្គជំនុំជម្រះសាលាដំបូង។ អាស្រ័យហេតុនេះហើយ មេធាវីការពារក្ដីមិនអាចដាក់បណ្ដឹងនេះនៅមុនពេលខ្លួនបញ្ចប់ និងបានដាក់ជូនបណ្ដឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ អាស្រ័យហេតុនេះហើយបានជាមេធាវីការពារក្ដី ខិតខំដាក់នូវបណ្ដឹងជំទាស់នេះ ដែលក្នុងពេលជាមួយគ្នាខ្លួនកំពុងតែរៀបចំបណ្ដឹងសាទុក្ខ និងរៀបចំសម្រាប់សវនាការនោះសំណុំរឿង ០០២/០១។

15. ដោយផ្អែកលើអំណះអំណាងខាងលើ មេធាវីការពារក្ដីអះអាងថា ដោយសារតែបញ្ហានានាដែលបង្កើតឲ្យមានបណ្ដឹងជំទាស់នេះ បានកើតឡើង បន្ទាប់ពីសវនាការបឋមសំណុំរឿង ០០២/០២ នោះ អនុលោមតាមវិធាន ៣៤(៣) និង (៤)(គ) នៃវិធានផ្ទៃក្នុង បណ្ដឹងជំទាស់នេះត្រូវចាត់ទុកថាដាក់ទាន់ពេលវេលា និងអាចទទួលយកបាន ពីព្រោះបណ្ដឹងនេះត្រូវបានធ្វើឡើង នៅពេលដែលមេធាវីការការពារក្ដីបានដឹងភ្លាមៗអំពីបញ្ហាទាំងនោះ និងនៅមុនពេលសេចក្ដីសម្រេចចុងក្រោយ

នៅក្នុងសំណុំរឿង ០០២/០២។

**ខ. ដោយបម្រើការនៅក្នុងអង្គការនីតិប្រតិបត្តិ និងតុលាការ ចៅក្រម យ៉ែន ពេជ្រសាលី បានបំផ្លាញដល់ការបង្ហាញឲ្យឃើញនូវឯករាជ្យភាព**

16. មេធាវីការពារក្តីសូមលើកឡើងថា លក្ខខណ្ឌចាំបាច់នៃឯករាជ្យរបស់អំណាចតុលាការគឺសំខាន់ណាស់ ក្នុងការធានាដល់ភាពឯករាជ្យ*ពីឥទ្ធិពលពីអង្គការនីតិប្រតិបត្តិ* និងដើម្បីធានាថា អំណាចជាមូលដ្ឋានរបស់រដ្ឋត្រូវនៅដាច់ពីគ្នា។ ដោយបម្រើការងារទាំងនៅក្នុងអង្គការនីតិប្រតិបត្តិ និងតុលាការ ហើយជាពិសេសនៅក្នុងតួនាទីនៅក្នុងអង្គារនីតិប្រតិបត្តិទាក់ទងទៅនឹងកិច្ចការអយ្យការនៃស្ថាប័នជាតិ ចៅក្រម យ៉ែន ពេជ្រសាលី បានបំផ្លាញដល់ការ*បង្ហាញឲ្យឃើញ*នូវឯករាជ្យភាពរបស់គាត់ ដោយបន្ថែមទៅនឹងការរំលោភលើរដ្ឋធម្មនុញ្ញកម្ពុជា។

17. ការចាត់តាំងចៅក្រម យ៉ែន ពេជ្រសាលី ខ្វះនូវ"ការធានាគ្រប់គ្រាន់ពីសម្ពាធខាងក្រៅ"ដូចដែលបានតម្រូវដោយលក្ខណៈវិនិច្ឆ័យរបស់តុលាការ EctHR ដោយសារតែវានឹងនៅក្រោមបញ្ជាផ្ទាល់របស់អង្គការនីតិប្រតិបត្តិរបស់រដ្ឋាភិបាល។ ជាងនេះទៅទៀតចៅក្រម យ៉ែន ពេជ្រសាលី បានប្រាក់បៀវត្សពីរ គឺមួយបានមកពីការងារនៅក្នុងអង្គការនីតិប្រតិបត្តិ និងមួយទៀតបានមកពីការងារជាចៅក្រមរបស់គាត់ ដែលប្រការនេះវាមិនគោរពតាមលក្ខណៈវិនិច្ឆ័យរបស់តុលាការ EctHR។ នៅក្នុងករណីនេះ ECtHR បានសម្រេចថា ស្ថានភាពបែបនេះមានន័យថា តុលាការជៀសមិនរួចនឹងមាន "ការពឹងផ្អែកខាងសម្ភារៈ ឋានានុក្រម និងរដ្ឋបាលទៅលើចៅហ្វាយនាយផ្ទាល់ និង[ធ្វើឲ្យប៉ះពាល់ដល់]ឯករាជ្យភាព និងភាពឥតលម្អៀងរបស់ពួកគាត់"។[16]

18. ដោយសារតែចៅក្រម យ៉ែន ពេជ្រសាលី ខ្វះនូវការបង្ហាញពីឯករាជ្យភាព អាស្រ័យហេតុនេះហើយគាត់មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រក្សាតួនាទីរបស់គាត់ជាចៅក្រមនៅ អ.វ.ត.ក និងអាស្រ័យហេតុនេះហើយត្រូវតែតែបានដកចេញពីសមាសភាពចៅក្រម។

**គ. ស្ថានភាពរបស់ចៅក្រម យ៉ែន ពេជ្រសាលី បង្ហាញឲ្យឃើញនូវភាពលម្អៀងទាក់ទងនឹងអំណះអំណាងជាក់លាក់នៅក្នុងបណ្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង**

19. មេធាវីការពារក្តីសូមលើកឡើងថា ដោយសារតែចៅក្រម យ៉ែន ពេជ្រសាលី មានតួនាទីពីរនៅក្នុង

---

[16] សេចក្តីសម្រេច ក្នុងរឿងក្តី Volkov កថាខណ្ឌ ១១៣។

រដ្ឋាភិបាលគឺ នៅក្នុងអង្គការនីតិប្រតិបត្តិ និងតុលាការ អ្នកអង្កេតឥតលម្អៀងនឹងយល់អំពីការលេចចេញនូវភាពលម្អៀងរបស់ចៅក្រម ប៉ែន ពេជ្រសាលី ទៅលើអំណះអំណាងរបស់មេធាវីការពារក្តីដែលបានលើកឡើងនៅកថាខណ្ឌទី៤៣ ដល់ ៥១ នៃបណ្តឹងជិតចិត្តចៅក្រមសាលាដំបូង។ នៅកថាខណ្ឌទាំងនោះមេធាវីការពារក្តីបានអះអាងថាចៅក្រម និល ណុន ចៅក្រម យ៉ា សាខន និងចៅក្រម យូរ ឧត្តរា ត្រូវតែបានដកចេញពីដំណើរការនីតិវិធីបន្តទៅទៀតប្រឆាំងនឹង នួន ជា ដោយហេតុផលថា តុលាការរបស់កម្ពុជា ត្រូវបានគ្រប់គ្រងដោយអង្គការនីតិប្រតិបត្តិ និងអាស្រ័យហេតុនេះហើយពុំមានឯករាជ្យភាព អំណះអំណាងនេះមិនមែនសម្រាប់តែតុលាការក្នុងស្រុកជាទូទៅនោះទេ តែថែមទាំងចៅក្រមជាតិនៅ អ.វ.ត.ក ផងដែរ។ ដោយសារតែការបង្ហាញពីភាពលម្អៀងបែបនេះ ចៅក្រម ប៉ែន ពេជ្រសាលី ត្រូវតែបានដកចេញពីសមាសភាពចៅក្រមនេះ។

## VI. **សំណើសុំ**

20. យោងតាមហេតុផលដូចបានរៀបរាប់ខាងលើ មេធាវីការពារក្តីសូមស្នើឲ្យ **(i)** អង្គជំនុំជម្រះទទួលយកពាក្យបណ្តឹងនេះ **(ii)** ចៅក្រម ប៉ែន ពេជ្រសាលី ត្រូវបានដកចេញសមាសភាពចៅក្រម **(iii)** ចៅក្រម ប៉ែន ពេជ្រសាលី លាចុះពីតំណែងដោយស្ម័គ្រចិត្ត អនុលោមតាមវិធាន ៣៤(៥) នៃវិធានផ្ទៃក្នុងខណៈពេលសម្រេចលើពាក្យសុំនេះ និង **(iv)** អង្គជំនុំជម្រះចាត់ទុកបណ្តឹងជិតចិត្តនេះជាបញ្ហាបន្ទាន់ ដោយសារលក្ខណៈពិសេសនៃបណ្តឹង។

សហមេធាវីការពារក្តីលោក នួន ជា

**សុន អរុណ** **Victor KOPPE**